00715730

E106

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជសដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១១

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ **សាធារណៈ** / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើជាបន្ទាន់របស់ អៀង សារី សុំពន្យារពេលវេលាកំណត់ដើម្បីដាក់បញ្ជីឯកសារ និង ទស្សនៈរបស់គាត់សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង**

---

<u>ដាក់ដោយ៖</u>

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

<u>ផ្ញើជូន៖</u>

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបំរុង យូរ ឧត្តរ៉ា

ចៅក្រមបំរុង Claudia FENZ

<u>ផ្ញើជូន៖</u>

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**


**ឯកសារដើម**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 15 / 07 / 2011
ម៉ោង (Time/Heure): 11:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

00715731



លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តទៅនេះដាក់សំណើសុំពន្យារពេលវេលាដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាងរបស់គាត់សម្រាប់ប្រធានជំនុំជម្រះបួនដំបូង ។ នៅសវនាការបឋម អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឲ្យភាគីផ្តល់បញ្ជីនេះមិនឲ្យហួសពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ឡើយ[1] ។ សំណើនេះគឺធ្វើឡើងជាចាំបាច់ព្រោះមេធាវីការពារក្តីត្រូវដាក់ចម្លើយតបចំនួនបួនត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១[2]។ ចម្លើយតបទាំងនេះសំខាន់ខ្លាំងណាស់ព្រោះវាគឺជាការឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដើម្បីកែប្រែច្បាប់ និងនីតិវិធីដែលមានជាធរមាននៅ អវតក ។ មេធាវីការពារក្តីបានស្នើសុំបន្ថែមពេលវេលាដើម្បីដាក់ចម្លើយតបចំនួនបីក្នុងចំណោមចម្លើយតបទាំងបួននេះ ប៉ុន្តែរហូតមក

---

[1] ប្រតិចារិកនៃសវនាការបឋមចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ នៅទំព័រទី២៥ "អង្គជំនុំជម្រះសាលាដំបូងបានស្នើឲ្យភាគីបង្ហាញពីឯកសារ និងវត្ថុតាងពីបញ្ជីលើកមុនរបស់ពួកគេនៃឯកសារ និងវត្ថុតាង ដែលត្រូវបានចាត់ទុកថាពាក់ព័ន្ធជាមួយផ្នែកដំបូងនៃសវនាការជំនុំជម្រះ មិនឲ្យហួសពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ឡើយ ។ សូមមើលផងដែរសារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់ផ្ញើទៅភាគីទាំងអស់: អង្គជំនុំជម្រះស្នើកែប្រែកាលបរិច្ឆេទកំណត់ទាក់ទងនឹងការរកឃើញចំនួនបីនាពេលថ្មីៗនេះរបស់សហព្រះរាជអាជ្ញា, ការជូនដំណឹងជាមុននៃកាលបរិច្ឆេទកំណត់សម្រាប់បញ្ជីឯកសារ និងវត្ថុតាងបន្ថែម (សម្រាប់ដំណាក់កាលដំបូងនៃការជំនុំជម្រះ) ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១១ ។ មន្ត្រីច្បាប់ជាន់ខ្ពស់បានគូសបញ្ជាក់ថា: អង្គជំនុំជម្រះបានជូនដំណឹងជាមុនទៅភាគីថាអង្គជំនុំជម្រះតម្រូវឲ្យភាគីទាំងអស់ បញ្ជាក់នៅក្នុងសវនាការបឋមមិនឲ្យហួសពីថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ថាតើឯកសារ និងវត្ថុតាងណាមួយ (ដែលបានមកពីបញ្ជីឯកសារ និងវត្ថុតាងមុននេះរបស់ពួកគេ) ត្រូវបានពួកចាត់ទុកថាពាក់ព័ន្ធនៃផ្នែកដំបូងនៃសវនាការជំនុំជម្រះ ។ ការបញ្ជាក់ជាមុនទាំងនេះ ចាំបាច់ដើម្បីផ្តល់លទ្ធភាពឲ្យអង្គភាពបកប្រែឯកសារអាចដឹងពីស្ថានភាពនៃការបកប្រែរបស់ឯកសារដែលភាគីចាត់ទុកថាជាឯកសារគន្លឹះ និងដើម្បីឲ្យអង្គជំនុំជម្រះកំណត់អត្តសញ្ញាណកម្មការលំបាកដែលមិនទាន់ដោះស្រាយ ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

[2] សហព្រះរាជអាជ្ញាបានដាក់សំណើសំខាន់ចំនួនបួនដែលតម្រូវឲ្យមានការឆ្លើយតប៖ ទី១. សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌពាក់ព័ន្ធនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១, ឯកសារ E95, ទី២. សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាតាមវិធាន៩២ ទាក់ទងនឹងការទទួលយកចម្លើយជាលាយលក្ខណ៍អក្សររបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១, ឯកសារ E96, ទី៣. សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងកំណត់ឡើងវិញនៃអង្គហេតុដើម្បីដាក់ការរំលោភផ្លូវភេទឲ្យទៅជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាជាងឧក្រិដ្ឋកម្មប្រឆាំងនុស្សជាតិ និងអំពើអមនុស្សធម៌ដទៃទៀត ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១, ឯកសារ E99 និងទី៤ . សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាសហឧក្រិដ្ឋកម្មរួម ទម្រង់ III ជាជម្រើសនៃការទទួលខុសត្រូវ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១, ឯកសារ E100 ។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទត្រឹមថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ដើម្បីដាក់ចម្លើយតបទៅកាន់សំណើនីមួយៗ ។ សេចក្តីសម្រេចលើសំណើសុំបន្ថែមរយៈពេលកំណត់ ចុះថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០១១, ឯកសារ E107។

ទល់ពេលនេះមិនទាន់ទទួលបានការសម្រេចពីអង្គជំនុំជម្រះសាលាដំបូងនៅឡើយទេ[3] ។ មេធាវីការពារក្តីប៉ាន់ស្មានថាខ្លួនត្រូវតែពិនិត្យមើលឯកសារប្រហែលពី២,៥០០ ទៅ៣,០០០ ទំព័របន្ថែមទៀតមុនពេលអាចបញ្ចប់បញ្ជីវត្ថុតាង និងឯកសាររបស់ខ្លួន ។ ដូច្នេះ មេធាវីការពារក្តីសូមស្នើដោយគោរពឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាបន្ថែមពេលវេលាកំណត់ដើម្បីដាក់បញ្ជីវត្ថុតាង និងឯកសាររបស់មេធាវីការពារក្តីរហូតដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១។ មេធាវីការពារក្តីយល់ឃើញថាការបន្ថែមពេលវេលាដែលបានស្នើសុំនេះ នឹងមិនពន្យារដំណើរការនីតិវិធីឡើយព្រោះសំណើទាំងបួនរបស់សហព្រះរាជអាជ្ញាត្រូវតែធ្វើការសម្រេចឱ្យបានមុនពេលចាប់ផ្តើមដំណើរការនីតិវិធី។

អាស្រ័យលើមូលហេតុដូចដែលបានគូសបញ្ជាក់នៅទីនេះ មេធាវីការពារក្តីសូមស្នើដោយគោរពឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាពន្យារកាលបរិច្ឆេទកំណត់សម្រាប់ឱ្យមេធាវីការពារក្តីដាក់បញ្ជីវត្ថុតាង និងឯកសាររបស់ខ្លួនសម្រាប់ប្រធានបទជំនុំជម្រះបួនដំបូងរហូតដល់ថ្ងៃទី៨ ខែសីហា ឆ្នាំ២០១១។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៥** ខែ **កក្កដា** ឆ្នាំ **២០១១**

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**

[3] សូមមើលសំណើរបស់ អៀង សារី សុំសេចក្តីសម្រេចជាបន្ទាន់ទាក់ទងនឹងបញ្ហាថាតើសហព្រះរាជអាជ្ញាអាចលើកសំណើសុំការកំណត់ឡើងវិញនៃអង្គហេតុនៅដំណាក់កាលនេះនៃនីតិវិធី និងសំណើសុំបន្ថែមពេលវេលាដើម្បីដាក់ចម្លើយតបទៅនឹងសំណើបែបនេះបានដែរទេ ប្រសិនបើចម្លើយតបមានការចំបាច់ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១, ឯកសារ E103 ។